Prince William County
PUBLIC SCHOOLS
*Providing A World-Class Education*

**KHMER-CAMBODIAN**

ជូនចំពោះ ឪពុកម្តាយ / អាណាព្យាបាល៖

យើងខ្ញុំសប្បាយរីករាយណាស់ដែលអ្នកនិងគ្រួសាររបស់អ្នកជាសមាជិកនៃសហគមន៍របស់យើងដែលឥឡូវនេះ ជាកន្លែងដែលប្រើប្រាស់ភាសាជាងមួយរយ។ សាលារដ្ឋ Prince William County ប្តេជ្ញាផ្តល់ការ*អប់រំគុណភាពលំដាប់ថ្នាក់ពិភពលោក* ដល់សិស្ស។ ដោយសារតែដៃគូ គ្រួសារ មានការយល់ដឹងពីដំណើរការនេះ យើងខ្ញុំសូមផ្តល់ព័ត៌មានចាំបាច់ដើម្បីជួយ ឪពុកម្តាយ និងអាណាព្យាបាលឲ្យយល់ និងចូលរួមជាមួយការអប់រំរបស់កូនៗពួកគាត់។

សាលាផ្តល់ឯកសារសិក្សាជាភាសាអង់គ្លេស ប៉ុន្តែយើងបកប្រែព័ត៌មាន និងឯកសារសំខាន់ៗជាបន្តបន្ទាប់ទៅជាភាសាដែលបានស្នើឲ្យប្រើច្រើនជាងគេនៅក្នុងតំបន់របស់យើង។

អ្នកនិយាយភាសាមួយចំនួនអាចទាញយកផលប្រយោជន៍ពីព័ត៌មានកំណៃថ្មី និងសំខាន់ៗ ជាប្រចាំដែលមានលើវិបសាយរបស់សាលា Prince William County — pwcs.edu—និងវិបសាយសាលារៀនឯកជន។ វិបសាយទាំងអស់មានឧបករណ៍បកប្រែល្បីៗ ដែលមានក្នុង Google ដោយផ្តល់ជូនការបកប្រែដែលបានកំណត់ជាង 50 ភាសា។ ការបកប្រែដោយប្រើប្រាស់កំព្យូទ័រជាធម្មតាមិនសូវត្រឹមត្រូវនោះទេតែការបកប្រែបែបនេះនៅតែផ្តល់បណ្តាញដែលមានតម្លៃចូលទៅក្នុងព័ត៌មានរបស់សាលា។ ប្រសិនបើអ្នកមិនមានលទ្ធភាពប្រើប្រាស់កុំព្យូទ័រក្នុងផ្ទះគ្រប់គ្រាន់នោះទេ អ្នកអាចប្រើប្រាស់កុំព្យូទ័រនៅតាមបណ្ណាល័យសាធារណៈណាមួយក៏បាន។

សំខាន់ជាងនេះទៀត នាយកដ្ឋានសាលាផ្តល់លទ្ធភាពប្រើប្រាស់អ្នកបកប្រែដែលមានវិជ្ជាជីវៈដើម្បីជួយឲ្យអ្នកនិយាយភាសាមួយចំនួនយល់ពីឯកសារដែលមានព័ត៌មានសំខាន់ៗស្តីពីសិទ្ធិទំនួលខុសត្រូវការរំពឹងទុកជាមុន និងបញ្ហាដទៃទៀតរបស់អាណាព្យាបាល និងសិស្សដែលជាប់ទាក់ទងនឹងការសិក្សាផលប្រយោជន៍ និងសេវាកម្មនានាដែលសិស្សអាចទទួលយកបាន។ អ្នកបកប្រែអាចជួយអ្នកតាមរយៈការប្រជុំរបស់អាណាព្យាបាលស្តីពីបញ្ហាទាំងអស់នេះដើម្បីធានាថាទិន្នន័យរបស់អ្នកគ្រប់គ្នាអាចបង្ហាញបាន និងងាយយល់។ សេវាទាំងនេះត្រូវបានផ្តល់ជូនដោយមិនគិតប្រាក់ពីគ្រួសារសិស្សទេ។

DR. STEVEN L. WALTS
*Superintendent of Schools*

P.O. BOX 389, MANASSAS, VA 20108 • WWW.PWCS.EDU

**ប្រើវិធីសាស្ត្រណាមួយក្នុងចំណោមវិធីសាស្ត្រទាំងនេះ នៅពេលអ្នកត្រូវការជំនួយការជាក់លាក់។**

- តាមប្រព័ន្ធអ៊ីនធឺណិត—ចូលទៅគេហទំព័រ translation.pwcs.edu
- តាមជួបផ្ទាល់—ទៅសាលារៀនកូនអ្នក។ អ្នកនិយាយភាសារបស់អ្នកអាចមិនមានវត្តមាននៅទីនោះ។ តែបុគ្គលិកនឹងប្រើខិត្តប័ណ្ណដើម្បីជួយអ្នក។

រាល់ករណីទាំងអស់ អ្នកនឹងត្រូវសួរបានសំណួរដើម្បីផ្តល់ជាព័ត៌មានដូចខាងក្រោម៖

- ឈ្មោះអ្នក និងឈ្មោះកូនរបស់អ្នក
- សាលារៀនកូនរបស់អ្នក កម្រិតថ្នាក់ និងឈ្មោះគ្រូ
- បុគ្គលដែលអ្នកចង់និយាយជាមួយ (ដោយឈ្មោះ ឬការងារ) និងប្រធានបទនៃការសន្ទនា និង
- លេខទូរស័ព្ទ និងពេលវេលាដែលអ្នកអាចទទួលការទំនាក់ទំនងបាន

- ប្រសិនបើកូនរបស់អ្នកនាំសារស្តីពីការស្នើសុំជួបប្រជុំមួយមកពីសាលា ឬបើអ្នកចង់រៀបចំការពិភាក្សាជាមួយគ្រូ ឬជាមួយការិយាល័យសាលាដទៃទៀត សូមប្រើវិធីសាស្ត្រខាងលើដើម្បីស្នើសុំអ្នកបកប្រែមកជួយក្នុងការសន្ទនាដ៏សំខាន់ទាំងនេះ។ នឹងមាននរណាម្នាក់នឹងឆ្លើយតបមកអ្នកវិញយ៉ាងឆាប់រហ័សតាមដែលអាចទៅធ្វើបាន។

ការចូលរួមរបស់អ្នកអាចធ្វើឲ្យមានចំណុចខុសប្លែកវិជ្ជមានមួយក្នុងការអប់រំរបស់កូនអ្នក ហើយយើងចង់អ្នកជួយតាមរយៈការបង្កើតសេវាទាំងនេះសម្រាប់អ្នក។ យើងសង្ឃឹមថាលិខិតនេះមានទំនាក់ទំនងយ៉ាងច្បាស់លាស់ជាមួយការប្តេជ្ញាចិត្តរបស់សាលារដ្ឋ Prince William County ចំពោះកូនរបស់អ្នក និងអ្នក។ ខ្ញុំជឿជាក់ថាអ្នកនឹងចែករំលែកបំណងប្រាថ្នារបស់យើងទៅសិស្សរាល់គ្នាដើម្បីទទួលការអប់រំលំដាប់ថ្នាក់ពិភពលោក។

ដោយសេចក្តីស្មោះត្រង់



Dr. Steven Walts

នាយកសាលា

*ពេលចូលទៅគេហទំព័រ pwcs.edu សូមស្វែងរកភូគោលដែលមានពណ៌ចម្រុះដើម្បីជាក់ទីតាំងទំព័រដែលមានព័ត៌មានដែលបានពិពណ៌នាក្នុងសារនេះ។